# ឯកឧត្តម ចម ប្រសិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលាជាតិស្តីពីកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ នៃអង្គការពាណិជ្ជកម្មពិភពលោក WTO និងការបណ្តុះបណ្តាលលើការជូនដំណឹង ក្នុងក្របខ័ណ្ឌ WTO

បន្ទាប់ពីដំណើរការអស់រយៈពេល០២ថ្ងៃ សិក្ខាសាលាជាតិ ស្តីពីកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យនៃអង្គការ ពាណិជ្ជកម្មពិភពលោក WTO និងការបណ្តុះបណ្តាល លើការជូនដំណឹង ក្នុងក្របខ័ណ្ឌ WTO សហការរៀបចំដោយ អគ្គនាយកដ្ឋាន កាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម ជាមួយនិងទីភ្នាក់ងារព័ត៌មានអំពីពាណិជ្ជកម្មនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ (AITIC) ត្រូវបានប្រារព្ធពិធីបិទ នៅរសៀលថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១០ ក្រោមអធិបតីភាពឯកឧត្តម**ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។






មានប្រសាសន៍ក្នុង ពិធីបិទសិក្ខាសាលាជាតិ នោះឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានថ្លែងអំណរគុណដល់ទីភ្នាក់ងារព័ត៌មានអំពី ពាណិជ្ជកម្មនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ (AITIC) ចំពោះជំនួយដែល ផ្តល់តាមពេលកំណត់ និងមានតម្លៃតាមរយៈ អង្គសិក្ខាសាលារយៈពេល ០២ថ្ងៃនេះ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងអំណរគុណ ចំពោះលោកស្រី **GayatriKanth** អនុប្រធាននាយក ប្រតិបត្តិនៃទីភ្នាក់ងារ AITIC និង លោក **Maghespren Chinappen** ដែលអ្នកទាំងពីរបានធ្វើដំណើរពីទីឆ្ងាយ មកទីនេះដើម្បីធ្វើការ រៀបចំអង្គសិក្ខសាលានិងផ្តល់បទអន្តរាគមន៍ នៅក្នុងអង្គសិក្ខាសាលាដែលប្រព្រឹត្តិទៅ បានដំជោគជ័យនេះ ។ ឯកឧត្តមបានវាយតំម្លៃខ្ពស់ ដល់សិក្ខាកាមមកពី បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធនិងបញ្ហអនាម័យ និងភូតគាមអនាម័យ បានយកចិត្តទុកដាក់ជាខ្លាំង ចំពោះសិក្ខាសាលា រយៈពេល ០២ ថ្ងៃនេះទាក់ទងនិងកិច្ចពិភាក្សាបញ្ហា អនាម័យ និងភូតគាមអនាម័យ នៅកម្ពុជា ។

ឯកឧត្តមទេសរដ្ឋមន្ត្រី**ចម ប្រសិទ្ធ** បានបញ្ជាក់ថា: ដូចដែលយើងបានដឹងទាំងអស់គ្នាហើយវិធានការអនាម័យ និងភូតគាមអនាម័យ អាចនឹងក៏រិតលំហូរពាណិជ្ជកម្ម អាចគេត្រូវបានគេ ប្រើក្នុងគោលបំណងការគាំពារនិងអាចប្រើជាខែលសំរាប់ការការពារផលិតផលក្នុងស្រុករបស់ខ្លួនដើម្បីបញ្ចៀសការប្រកួតប្រជែងខាងសេដ្ឋកិច្ចផងដែរ ។ វាជាការសំខាន់ក្នុងការកូសបញ្ជាក់ នូវលក្ខណៈសំខាន់ៗ ក្នុងកិច្ចព្រមព្រៀង នៃការអនុវត្តន៏វិធានការ អនាម័យនិងភូតគាមអនាម័យ ដូចខាងក្រោម:

-កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ លើកទឹកចិត្តឱ្យយើងប្រើ ស្តង់ដាអន្តរជាតិ ដែលមានស្រាប់ ដូចជាស្តង់ដា CODEX ស្តង់ដា OIE និងស្តង់ដា IPPC ។

-ក្នុងកិច្ចព្រមព្រៀងនេះ ដែរយុត្តិកម្មមួយដែលមិនប្រើស្តង់ដា ទាំងនេះសំរាប់សុវត្ថិភាពម្ហូបអាហារ ការការពារសុខភាព សត្វនិងរុក្ខជាតិ គឺហេតុផលវិទ្យាសាស្ត្រ ហើយប្រការនេះនឹង ធ្វើឱ្យមានទំនាស់ពាណិជ្ជកម្មកាន់តែកើនឡើង ។

ក្នុងក្របខ័ណ្ឌ នៃយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល កម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាម ជនបទ បានកំណត់គោលនយោបាយការធ្វើ ពិពិធកម្មសេដ្ឋកិច្ច តាមរយៈការបង្កើនការនាំចេញផ្នែកជាច្រើននិងការធ្វើពិពិធកម្មផលិតផលកសិផល តាមរយៈការធ្វើឱ្យវិស័យឯកជនទទួលបានសេវាកម្មអនាម័យ និងភូត គាមអនាម័យល្អប្រសើរ ។ ដូច្នេះក្នុងយថាទស្សន៏ នៃការបំពេញកាតព្វកិច្ច ក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកស្របជាមួយនិងតំរូវការក្នុងស្រុកយើងបានបង្កើតការិយាល័យព័ត៌មានដូចជា: ចំណុចទំនាក់ទំនងអនាម័យ និងភូតគាមអនាម័យ និងអាជ្ញាធរជូនដំណឹងជាតិ ។

យើងបានឯកភាពអនុម័តយកបទដ្ឋាន CODEX ជាបញ្ញត្តិ កម្មបច្ចេកទេសម្ហូបអាហារ លើផ្នែកណាដែលទាក់ទិន

និងកម្ពុជា ។ គោលនយោបាយ នេះអាចនឹងធ្វើឱ្យផលិតផល របស់យើងអាចមានលទ្ធភាព ចូលទីផ្សារបាន និងដើម្បីជៀសវាងទីផ្សារក្នុងស្រុករបស់យើងក្លាយជាកន្លែងចាក់សំរាមសំរាប់ម្ហូបអាហារដែលមានស្តង់ដាទាបនិងម្ហូបអាហារមិនមានសុវត្ថិភាព ក្នុងករណីដែលយើង អនុម័តយកស្តង់ដាទាបជាងនេះ ។ នៅពេលនេះសមត្ថភាព និងលទ្ធភាព នៃមន្ទីរពិសោធន៏ ធ្វើតេស្តនិងសមត្ថភាព ក្នុងការវាយតម្លៃហានិភ័យ ចំពោះសុវត្ថិភាពម្ហូបអាហារ រឺសុខភាពសត្វ និងរុក្ខជាតិ ត្រូវបានពង្រឹងយ៉ាងខ្លាំងក្លា តាមរយៈការគាំទ្ររបស់រាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ ។

ទោះបីយើងទទួលបានស្នាដៃយ៉ាងនេះក្តីយើងនៅមានការងារជាច្រើនដើម្បីរៀនសូត្រនិងធ្វើការងារបន្តទៀត ។ ឯកឧត្តមទេសរដ្ឋមន្ត្រី**ចម ប្រសិទ្ធ** បានស្នើឱ្យមន្ត្រីយើងបន្តប្តេជ្ញាចិត្តរបស់ខ្លួនទៀតដើម្បីប្រើចំណេះដឹងនិងបទពិសោធន៍ដែលទទួលបានពីអង្គសិក្ខាសាលានេះជំរុញឱ្យមានប្រសិទ្ធិភាព នៃអង្គសិក្ខាសាលាផ្សេងៗទៀត ពាក់ព័ន្ធនិងអនាម័យនិងភូតគាមអនាម័យ ផ្តល់ជាប្រយោជន៍ដល់អ្នកប្រើប្រាស់កម្ពុជាផលិតករអ្នកនាំចេញនិងអ្នកនាំចូល ។

ជាទីបញ្ចប់ ដើម្បីធានាឱ្យវិធានការអនាម័យ និងភូតគាមអនាម័យនេះកាន់តែ ប្រសើរថែមទៀត ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានស្នើសុំឱ្យទីភ្នាក់ងារ (AITIC) ផ្តល់ជំនួយបច្ចេកទេស ដល់កម្ពុជា និងផ្តល់មូលនិធិទៅលើផ្នែកអនាម័យ និងភូតគាមអនាម័យនេះឱ្យកាន់តែស៊ីជំរៅថែមទៀតទាំងផ្នែកច្បាប់ និងផ្នែកបច្ចេកទេស ។